រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨

## ប្រកាសណែនាំលេខ ៨៤៨ សហវ.ជ

## ស្តីពីការបិទបញ្ជីចំណូល ចំណាយថវិការដ្ឋ និងធ្វើរបាយការណ៍បូកសរុបសំរេចទូទាត់ថវិកា ឆ្នាំ ១៩៩៨

យោងមាត្រា ៤ ជំពូក១ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខ ០១/នស/៩៣ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៣ បានកំណត់ថា ឆ្នាំថវិកាត្រូវចាប់ផ្តើមពីថ្ងៃទី ០១ ខែ មករា និង បញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ។ ដូច្នេះដើម្បីធានាឲ្យការបិទបញ្ជីចំណូល ចំណាយថវិការដ្ឋ និងធ្វើរបាយការណ៍ បូកសរុបសំរេចទូទាត់ថវិការដ្ឋប្រចាំឆ្នាំ ១៩៩៨ ប្រព្រឹត្តទៅបានត្រឹមត្រូវ និងទាន់ពេលវេលានោះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំស្តីពីនីតិវិធីបច្ចេកទេសដូចតទៅ ៖

១- ការធ្វើនីយ័តភាពឥណទានទាំងឡាយត្រូវបញ្ចប់នៅថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៩៨ ។ ដូច្នេះ គ្រប់ក្រសួង-ស្ថាប័ន និងខេត្ត-ក្រុងទាំងអស់ ត្រូវបញ្ជូនសំណើលិខិតស្នើសុំនីយ័តភាពឥណទានមកដល់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យ៉ាងយូរត្រឹមថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៩៨ ។

២- អាណាប័កដើមខ្សែ (អ្នកបញ្ជាចំណូល ចំណាយផ្ទាល់ខ្លួន) និងអាណាប័កតាមការផ្ទេរសិទ្ធិទាំងឡាយត្រូវ ៖

- ខិតខំប្រមូលចំណូលដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួន បង់ចូលថវិការដ្ឋទាំងអស់យ៉ាង យូរត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ បើមានការយឺតយ៉ាវបង់ចូលថវិកាក្រោយថ្ងៃកំណត់នេះ រតនាគារជាតិ និងរតនាគារខេត្ត-ក្រុងនឹងកត់ត្រាចូលជាចំណូលថវិការដ្ឋ ឆ្នាំ ១៩៩៩ ។

- បញ្ឈប់ការបញ្ជូនអាណត្តិបើកប្រាក់ ឬ បញ្ជាចំណាយទៅរតនាគារត្រឹមថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ១៩៩៨ ។ ដូច្នេះគ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញនៅខេត្ត-ក្រុងត្រូវប្រមូលសក្ខីប័ត្រ ដើម្បីធ្វើអាណត្តិបើកប្រាក់ ឬ បញ្ជាចំណាយឆ្លងទិដ្ឋាការមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុឲ្យបានមុនថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៨ ។

៣- ក្រសួង-ស្ថាប័ន ឬ មន្ទីរជំនាញនៅខេត្ត-ក្រុង ដែលបានបុរេប្រទានប្រាក់ពីរតនាគារជាតិ ឬរតនាគារខេត្ត-ក្រុងត្រូវប្រមូលសក្ខីប័ត្រ ដើម្បីរៀបចំអាណត្តិបើកប្រាក់ ឬ បញ្ជាចំណាយសំរាប់ធ្វើការទូទាត់ប្រាក់បុរេប្រទានឲ្យបានមុនថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៨ ។

៤- រតនាគារជាតិត្រូវបញ្ឈប់ ការដកសាច់ប្រាក់ពីគណនីរដ្ឋលេខាបុរេប្រទានត្រឹមថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ១៩៩៨ ដូច្នេះរដ្ឋលេខាករត្រូវគិតគូរអំពីតំរូវការចំណាយរហូតដល់ដំណាច់ឆ្នាំ១៩៩៨ ដើម្បីស្នើសុំដក សាច់ប្រាក់ឲ្យបានមុនថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៩៨ ។ ក្នុងរយៈពេលពីថ្ងៃទី ១៥ ដល់ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៨ រដ្ឋលេខាករបុរេប្រទានទាំងអស់ត្រូវប្រមូលសក្ខីបត្រ និងលិខិតយុត្តិការណ៍ ដើម្បីធ្វើអាណត្តិបើក ប្រាក់ឆ្លងទិដ្ឋាការមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ និងបញ្ជូនទៅរតនាគារជាតិត្រឹមថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៨ ។

៥- កិច្ចប្រតិបត្តិការរតនាគារសំរាប់ថវិការដ្ឋឆ្នាំ ១៩៩៨ ត្រូវបញ្ចប់ត្រឹមថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩៩ ។ ហួសពេលនេះ បើរតនាគារជាតិ ឬ រតនាគារខេត្ត-ក្រុងនៅតែគ្មានលទ្ធភាពដោះស្រាយសាច់ប្រាក់ផ្តល់នោះទេ ត្រូវធ្វើសលាកបត្របញ្ជាចំណាយ ដែលមានលំអិតលើភាគឥណទាន ដោយមិនត្រូវកត់ត្រាជាចំណាយថវិការដ្ឋទេ ។ លើកលែងតែចំណាយជំពូក ១០ របបអ្នកជំងឺ ប្រាក់ឧបត្ថម្ភភូមិ ឃុំ និង ជំពូក៣១ ។

៦- ចាប់ពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៨ ក្រសួង-ស្ថាប័នរដ្ឋបាលកណ្តាលត្រូវដំណើរការធ្វើការសម្រេចចំណាយជាមួយមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ នូវចំណាយជាប្រចាំដែលមានតំរូវការជាបន្ទាន់សំរាប់ចំណាយក្នុងខែមករា ឆ្នាំ១៩៩៩ ជាពិសេសចំណាយសំរាប់ប្រាក់បៀវត្ស និងប្រាក់វិភាជន៍សង្គម ដោយផ្អែកលើកិច្ចមួយភាគដប់ពីរ នៃឥណទានឆ្នាំ ១៩៩៨ ដែលរដ្ឋសភាបានអនុម័ត ។

៧- ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ១៩៩៩ តទៅ រាល់ប្រតិបត្តិការចំណូល ចំណាយថវិការដ្ឋថ្មី ត្រូវកត់ត្រាចូលក្នុងគណនីថវិការដ្ឋ ឆ្នាំ ១៩៩៩ ។

៨- ចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ១៩៩៩ រតនាគារជាតិត្រូវដំណើរការបូកសរុបកិច្ចប្រតិបត្តិការរតនាគារទូទាំងប្រទេស អំពីការអនុវត្តន៍ចំណូល ចំណាយថវិការដ្ឋឆ្នាំ១៩៩៨ ហើយបញ្ជូនសលាកបត្រមកនាយកដ្ឋានថវិកាយ៉ាងយូរត្រឹមថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ ។

៩- ចាប់ពីថ្ងៃទី០១ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ គ្រប់មន្ទីរនៅតាមខេត្ត-ក្រុងត្រូវធ្វើការផ្ទៀងផ្ទាត់តួលេខចំណូល ចំណាយរបស់អង្គភាពខ្លួនឲ្យបានស៊ីគ្នាជាមួយរតនាគារ និងមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ហើយ ធ្វើរបាយការណ៍បូកសរុបសំរេចទូទាត់ថវិការបស់ខ្លួនរួចផ្ញើមកមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងក្រសួងសាមី ចំនួន ០២ច្បាប់ ឲ្យបានមុនថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ ។ មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៅតែមានភារកិច្ចបូកសរុបសំរេចទូទាត់ចំណូល ចំណាយថវិការបស់ខេត្ត-ក្រុង រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយក ដ្ឋានថវិកា) ចំនួន ០២ច្បាប់ ឲ្យបានមុនថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ ជាកំហិត ។ ចំពោះក្រសួង-ស្ថាប័ន រដ្ឋបាលកណ្តាលត្រូវធ្វើការផ្ទៀងផ្ទាត់តួលេខចំណូល-ចំណាយរបស់ខ្លួនជាមួយរតនាគារជាតិ ដើម្បីឲ្យបានស៊ីគ្នា ហើយធ្វើរបាយការណ៍បូកសរុបទូទាត់ចំណូល-ចំណាយថវិការបស់ក្រសួង-ស្ថាប័ន ដោយមានបញ្ចូលចំណូល-ចំណាយថវិការបស់មន្ទីរនានាក្រោមឱវាទនៅតាមខេត្ត-ក្រុងផង រួចផ្ញើមកក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ចំនួន ០២ច្បាប់ ឲ្យបានមុនថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ ១៩៩៩ ជាកំហិត ។

របាយការណ៍បូកសរុបសំរេចទូទាត់ចំណូល-ចំណាយថវិកា ត្រូវធ្វើទៅតាមតារាងគំរូដូចមានជូនភ្ជាប់មកជាមួយនេះ ហើយក្រសួង-ស្ថាប័ន និងមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ឲ្យបានតាមការកំណត់ដូចខាងលើជាកំហិត ដើម្បីនាយកដ្ឋានថវិកាមានលទ្ធភាពធ្វើការបូកសរុប រៀបចំសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋ សំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៨ ដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យ សំរេច និងរដ្ឋសភាពិនិត្យអនុម័តឲ្យបានទាន់ពេលវេលា ។

ហត្ថលេខា និង ត្រា

**គាត ឈន់**

***

ក្រសួង......    **តារាងបូកសរុបសំណល់ថវិការដ្ឋ**    **ព្រះរាជាណាចក្រកម្ពុជា**

លេខកូដ......    **សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨**    **ជាតិ សាសនា ព្រះមហាក្សត្រ**

តារាងឧបសម្ព័ន្ធ ១

| ជំពូក | ប្រការ | គណនី | អនុគណនី | បរិយាយ ចំណាត់ថ្នាក់ចំណូល | ច្បាប់ ហិរញ្ញវត្ថុកែតម្រូវ | អនុវត្ត ជាក់ស្តែង | សមាមាត្រ ប្រៀបធៀប | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ = ៣/២ | |
| | | | | ក.ផ្នែករដ្ឋបាលកណ្តាល | | | | |
| | | | | ខ.ផ្នែកមន្ទីរជំនាញនៅ តាមខេត្ត-ក្រុង | | | | |
| | | | | សរុបរួម | | | | |

| ហត្ថលេខា និង ត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា | ហត្ថលេខា |
|---|---|---|---|
| ប្រធានរតនាគារជាតិ | រដ្ឋមន្ត្រី | ប្រធានគណនេយ្យ | អ្នកធ្វើតារាង |

★★★

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង...
លេខកូដ...

**តារាងបូកសរុបសំណុំលទ្ធិការរដ្ឋ**
**សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨**

តារាងឧបសម្ព័ន្ធ ២

| ជំពូក | ប្រការ | កថាខណ្ឌ | អនុកថាខណ្ឌ | ចំណាយ ចំណាត់ថ្នាក់តាមជំពូក | ច្បាប់ហិរញ្ញវត្ថុដើមឆ្នាំ | ចលនាឥណទាន | អនុវត្តជាក់ស្តែង | សមាមាត្រប្រៀបធៀប | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ = ៤/៣ | |
| | | | | I.ផ្នែករដ្ឋបាលកណ្តាល | | | | | |
| | | | | II.ផ្នែកមន្ទីរជំនាញនៅតាមខេត្ត-ក្រុង | | | | | |
| | | | | សរុបរួម | | | | | |

| | | | |
|---|---|---|---|
| ហត្ថលេខា និង ត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា | ហត្ថលេខា |
| ប្រធានធនាគារជាតិ | រដ្ឋមន្ត្រី | ប្រធានគណនេយ្យ | អ្នកធ្វើតារាង |

★★★

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង...
លេខកូដ...

**តារាងបូកសរុបសំណល់ថវិការដ្ឋ**
**សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨**

តារាងឧបសម្ព័ន្ធ ៣

| ជំពូក | ប្រការ | កថាខណ្ឌ | អនុកថាខណ្ឌ | បរិយាយ ធាតុពាក់ព័ន្ធចំណូល | ច្បាប់ ហិរញ្ញវត្ថុដើមឆ្នាំ | អនុវត្ត ជាក់ស្តែង | សមាមាត្រ ប្រៀបធៀប | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ = ៣/២ | |
| | | | | | | | | |
| | | | | សរុបរួម | | | | |

| | | | | |
|---|---|---|---|---|
| ហត្ថលេខា និង ត្រា | ហត្ថលេខា និងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខា |
| ប្រធានរតនាគារ | អភិបាល | ប្រធានមន្ទីរសេដ្ឋកិច្ច | ប្រធានមន្ទីរ | អ្នកធ្វើតារាង |
| ខេត្ត-ក្រុង | ខេត្ត-ក្រុង | និងហិរញ្ញកិច្ច | | |

★★★

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង.........
លេខកូដ..........

តារាងបូកសរុបសំណូលថវិការដ្ឋ
សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨

តារាងឧបសម្ព័ន្ធ ៤

| ជំពូក | ប្រការ | កថាខណ្ឌ | អនុកថាខណ្ឌ | បរិយាយ ចំណាត់ថ្នាក់ចំណូល | ច្បាប់ហិរញ្ញវត្ថុដើមឆ្នាំ | ចលនាឥណទាន | អនុវត្តជាក់ស្តែង | សមាមាត្រប្រៀបធៀប | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ = ៤/៣ | |
| | | | | សរុបរួម | | | | | |

| ហត្ថលេខា និង ត្រា | ហត្ថលេខា និងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខា |
|---|---|---|---|---|
| ប្រធានរតនាគារ | អភិបាល | ប្រធានមន្ទីរសេដ្ឋកិច្ច | ប្រធានមន្ទីរ | អ្នកធ្វើតារាង |
| ខេត្ត-ក្រុង | ខេត្ត-ក្រុង | និងហិរញ្ញកិច្ច | | |

★★★